# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍សារព័ត៌មាន ដោយលោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ ២០១១

ខ្ញុំជិតនឹងបញ្ចប់បេសកកម្មស្វែងរកការពិតស្តីពីសិទ្ធិមនុស្សលើកទីប្រាំរបស់ខ្ញុំនៅកម្ពុជាហើយ។ បេសកកម្មនេះគឺជាបេសកកម្មបន្តពីបេសកកម្មរបស់ខ្ញុំកាលពីលើកមុន ដែលបានប្រព្រឹត្តទៅកាលពីខែកុម្ភៈឆ្នាំនេះ។ បន្ថែមពីលើការតាមឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សទូទៅនៅក្នុងប្រទេសកម្ពុជា ខ្ញុំបានផ្តោតបេសកកម្មលើកនេះ លើការបន្តពិនិត្យតួនាទីរបស់សភា ដែលជាផ្នែកមួយនៃការងាររបស់ខ្ញុំ ក្នុងការវាយតំលៃលើស្ថាប័នរដ្ឋនានា ដែលទទួលខុសត្រូវលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ។ ខ្ញុំបានជួបប្រាស្រ័យទាក់ទងជាមួយមនុស្សមួយចំនួនធំ ដែលមកពីវិស័យផ្សេងៗគ្នា រួមមានប្រធានរដ្ឋសភា ប្រធានគណៈបក្សនយោបាយនានាដែលមានអាសនៈក្នុងសភា សមាជិកសភាមួយចំនួន មន្ត្រីរដ្ឋាភិបាលផ្សេងៗ តំណាងនានានៃទីភ្នាក់ងារអ.ស.ប និងម្ចាស់ជំនួយ អ្នកការទូត តំណាងអង្គការក្រៅរដ្ឋាភិបាលនិងសហជីព ក៏ដូចជា ប្រជាពលរដ្ឋឯកជននានា។ ខ្ញុំក៏បានធ្វើទស្សនកិច្ចនៅតំបន់បឹងកក់ ដែលគ្រួសារប្រជាពលរដ្ឋ មួយចំនួនធំកំពុងប្រឈមនឹងការគម្រាមបណ្តេញចេញ និងតំបន់មួយក្នុងខណ្ឌសែនសុខ ជាកន្លែងដែលគ្រួសារមួយចំនួនត្រូវបានបង្ខំឲ្យចាកចេញកាលពីសប្តាហ៍កន្លងទៅថ្មីៗនេះ ហើយក៏បានជួបជាមួយបុគ្គលម្នាក់ដែលជាប់ចោទពីបទញុះញង់ផងដែរ។

ទន្ទឹមនឹងស្ថានការណ៍សិទ្ធិមនុស្សទូទៅបានប្រសើរឡើងនៅក្នុងវិស័យមួយចំនួនក្តី ក៏នៅក្នុងវិស័យមួយចំនួនផ្សេងទៀត មិនទាន់បានប្រសើរឡើងនៅឡើយ។ ឧទាហរណ៍ជាក់ស្តែង គឺសិទ្ធិខាងដីធ្លី ការបណ្តេញចេញ និងសេរីភាពខាងការបញ្ចេញមតិ។ ដោយសារតែភ័យខ្លាចប្រឈមនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ បទផ្សាយព័ត៌មានមិនពិត និងបទញុះញង់ប្រឆាំងនឹងខ្លួន មនុស្សជាច្រើនដូចជាអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយ ព្រមទាំងបុគ្គលឯកជននានាហាក់ដូចជាកំពុងរឹតត្បិតការបញ្ចេញមតិខ្លួនឯង។ ខ្ញុំមានកង្វល់ចំពោះការប្រើប្រាស់ការចោទប្រកាន់បែបនេះប្រឆាំងនឹងសកម្មជនការពារសិទ្ធិខាងដីធ្លី និងបុគ្គលនានា ដែលធ្វើការទាមទារសិទ្ធិលើដីធ្លីដែលមានទំនាស់។ ខ្ញុំមានការស្រងាកចិត្តដោយបានឮអំពីការ ប្រើប្រាស់កំលាំងមិនសមាមាត្រដោយអាជ្ញាធរអនុវត្ត

ច្បាប់ នៅក្នុងអំឡុងពេលធ្វើបាតុកម្មដោយសន្តិវិធីដោយក្រុមប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី។ ជាអាទិ៍ អំពើហិង្សាប្រឆាំងការធ្វើបាតុកម្មដោយប្រជាពលរដ្ឋមកពីតំបន់បឹងកក់ កាលពីខែមេសា ឆ្នាំ២០១១ គឺជារឿងដែលគួរឲ្យសោកស្តាយជាទីបំផុត។ ទោះជាយ៉ាងដូច្នោះក្តី ខ្ញុំរីករាយ ដោយបានដឹងអំពីការរៀបចំឲ្យមានកិច្ចសន្ទនានាពេលថ្មីៗនេះ រវាងសហគមន៍បឹងកក់ដែលនៅសេសសល់ និងសាលារាជធានីភ្នំពេញ ហើយខ្ញុំសង្ឃឹមថានឹងមានដំណោះស្រាយមួយដែលអាចទទួលយកបានទាំងសងខាង។

ខ្ញុំក៏មានការពេញចិត្តផងដែរ ដោយបានដឹងថាក្រសួងពាក់ព័ន្ធនានាបានបើកឲ្យមានដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីព្រាងច្បាប់ស្តីពីសហជីព ជាមួយភាគីពាក់ព័ន្ធនានា។ នេះជាការអនុវត្តន៍ដ៏ប្រសើរមួយ ហើយខ្ញុំសង្ឃឹមថា ការអនុវត្តន៍បែបនេះនឹងត្រូវគេយកទៅធ្វើតាមនៅក្នុងវិស័យផ្សេងៗទៀងផងដែរ។ ទោះជាដូច្នេះក្តី ការពិគ្រោះយោបល់បែបនោះត្រូវការមានអត្ថន័យ ហើយខ្ញុំសង្ឃឹមថា សេចក្តីព្រាងចុងក្រោយនៃច្បាប់ទាំងនេះមានរួមបញ្ចូលនូវការស្នើនានា ដែលត្រូវបានផ្តល់ឲ្យនៅអំឡុងពេលពិគ្រោះយោបល់ទាំងនោះ ដើម្បីឲ្យច្បាប់ទាំងនេះក្រោយពីអនុម័តរួច នឹងផ្តល់លទ្ធភាពឲ្យសមាគម និងអង្គការដែលពាក់ព័ន្ធនានាធ្វើការពង្រឹង ជាជាងរិតត្បិតសកម្មភាពរបស់ពួកគេ។

ទាក់ទិននឹងសភា ខ្ញុំមានការពេញចិត្ត ដោយឃើញការរីកចំរើនដែលប្រទេសនេះសម្រេចបាន ក្នុងការបង្កើតវិធានអនុវត្តន៍របស់សភា នៅក្នុងអំឡុងពេលដ៏ខ្លីមួយ។ ដោយដឹងថា ប្រទេសនេះទើបតែទទួលបានស្ថេរភាពនយោបាយ គិតពីឆ្នាំ២០០៣ មក ដូច្នេះរាល់សម្មិទ្ធិផលដែលសម្រេចបានតាំងពីពេលនោះមក គឺជារឿងគួរឲ្យកោតសរសើរជាទីបំផុត។ ទោះជាដូច្នោះក៏ដោយ ក៏នៅមានការឆកល្វែងមួយចំនួននៅក្នុងការបំពេញមុខងាររបស់សភាជាទូទៅ ហើយជាពិសេសគឺរដ្ឋសភា។ ជាបឋមគឺដំណើរការធ្វើច្បាប់គ្រប់ដំណាក់កាលទាំងអស់គួរតែមានតម្លាភាពជាងនេះ។ សញ្ញាណនៃពហុបក្ស និងសេរីនិយម ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានតាក់តែងឡើង ដើម្បីធានាបរិយាកាសឲ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមនៅក្នុងដំណើរការនៃការធ្វើលទ្ធិប្រជាធិបតេយនីយកម្ម និង ការកសាងប្រទេស។

ខ្លឹមសារ និងស្មារតីនៃរដ្ឋធម្មនុញ្ញតម្រូវឲ្យគណៈបក្សនយោបាយដែលគ្រប់គ្រងអំណាចណាមួយ ទោះបីជាខ្លួនមានសម្លេងច្រើនលើសលុបនៅក្នុងសភាយ៉ាងណាក៏ដោយ ដាច់ខាតត្រូវតែគោរពរបបពហុបក្ស សេរីនិយម និងសិទ្ធិមនុស្ស។ ដូច្នោះហើយ គណៈបក្សនយោបាយណាមួយ ទោះបីជាគណៈបក្សនោះមានសម្លេងភាគច្រើន ពីរភាគបីក្នុងសភាក៏ដោយ ក៏គណៈបក្សនោះពុំគួរអនុម័តច្បាប់ដែលកាត់បន្ថយវិសាលភាពនៃសិទ្ធិមនុស្ស ដែលត្រូវបាន ធានាដោយរដ្ឋធម្មនុញ្ញឡើយ។ ទោះជាដូច្នោះក៏ដោយ មានច្បាប់មួយចំនួនដែលបានអនុម័តកាលពីពេលកន្លងមកនេះ (រួមមានលិខិតបទដ្ឋានគតិយុត្ត និងអនុក្រឹតមួយចំនួន) ដែលបានមាននិន្នាការរឹតត្បិតដល់វិសាលភាពនៃសិទ្ធិរបស់ប្រជាពលរដ្ឋ។ សភានៅកម្ពុជាមានលទ្ធភាពតិចតួចបំផុត ក្នុងការរារាំងអង្គនីតិប្រតិបត្តិចំពោះការបង្កើតលិខិតបទដ្ឋានគតិយុត្តដែលមានចរិតលក្ខណៈដូចនេះ។ ដើម្បីឲ្យលទ្ធិប្រជាធិបតេយ្យអាចដំណើរការទៅដោយសមស្រប សមាជិកម្នាក់ៗ

របស់សភា គួរតែមានលទ្ធភាពក្នុងការអនុវត្តន៍សេរីភាពនៃការបញ្ចេញមតិរបស់ខ្លួន។ វិធាន និងនីតិវិធីផ្ទៃក្នុងបច្ចុប្បន្ន មួយចំនួនរបស់រដ្ឋសភា មិនផ្តល់លទ្ធភាពងាយស្រួលឲ្យសមាជិកគ្រប់រូប ប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិរបស់ខ្លួននោះទេ នៅពេលត្រួតពិនិត្យគណនីយភាពរបស់អង្គនីតិប្រតិបត្តិ និងការពារសិទ្ធិប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ។

លិទ្ធិប្រជាធិបតេយ្យគឺសំដៅដល់កិច្ចសន្ទនា និងការជជែកដេញដោលគ្នាលើរាល់បញ្ហាដែលជាផលប្រយោជន៍ជាតិ ហើយជាពិសេសនោះគឺក្នុងករណីសភាតែម្តង ដែលតាមនិយមន័យ សភាគឺជាកន្លែងមួយ ដែលសមាជិកសភាគ្រប់រូបអាចជជែកដេញដោលគ្នាដោយសេរីលើបញ្ហានានាដែលជាផលប្រយោជន៍ជាតិ។ ដោយហេតុផលនេះហើយទើបសមាជិកសភាត្រូវបានផ្តល់នូវអភ័យឯកសិទ្ធិ។ ទោះជាដូច្នេះក្តី នៅរយៈពេលកន្លងទៅថ្មីៗនេះ វិសាលភាពសំរាប់សមាជិកសភានៅកម្ពុជាក្នុងការចូលរួមជជែកដេញដោលត្រូវបានកំរិត និងមានសមាជិកសភាមួយចំនួនត្រូវបានដកអភ័យឯកសិទ្ធិ សូម្បីតែការបញ្ចេញមតិអំពីបញ្ហានានា ដែលជាផលប្រយោជន៍ជាតិក្តី។ លើសពីនេះទៅទៀត ភាគច្រើននៃសមាជិកសភាទាំងនោះ មិនត្រូវបានគេផ្តល់ឱកាសឲ្យលើកអំណះអំណាងការពារខ្លួនឡើយ ដែលជាការផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋានស្តីពីយុត្តិធម៌ធម្មជាតិ នេះមិននិយាយដល់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិផង។ លទ្ធិប្រជាធិបតេយ្យមួយដែលដំណើរការត្រឹមត្រូវ ទាមទារឲ្យមានការពិនិត្យមើលយ៉ាងមានប្រសិទ្ធភាពលើសកម្មភាពរបស់អង្គនីតិប្រតិបត្តិ និងលើក្រុមដែលមានសម្លេងភាគច្រើន។

វិធានអនុវត្តន៍របស់សភាកំពុងត្រូវបានបង្កើតឡើង ប៉ុន្តែវាទំនងជាត្រូវប្រើរយៈពេលយូរទៀត ដើម្បីឲ្យគេអាចទទួលយកមតិប្រឆាំងដ៏មានប្រសិទ្ធភាពមួយ។ វប្បធម៌ដំណើរការត្រឹមត្រូវរបស់សភា គឺជាអ្វីដែលកម្ពុជាត្រូវការដើម្បីបោះជំហានទៅមុខ។ អ្វីដែលជាសេចក្តីត្រូវការនៅក្នុងប្រទេសកម្ពុជានោះ គឺឆន្ទៈនយោបាយ ក្នុងការពន្លឿនដំណើរការលទ្ធិប្រជាធិបតេយនីយកម្មរបស់ប្រទេស។ ស្ថាប័ននានាដែលចាំបាច់សម្រាប់ដំណើរការលទ្ធិប្រជាធិបតេយនីយកម្មមានស្រាប់ហើយ ក៏ប៉ុន្តែដំណើរនៃការកសាងស្ថាប័នទាំងនោះឲ្យទៅជាស្ថាប័នរដ្ឋដែលឯករាជ មិនលំអៀង និងមានប្រសិទ្ធភាព នៅមានសភាពយឺតយ៉ាវនៅឡើយ។

បើនិយាយអំពីវិស័យតុលាការវិញ មានករណីអយុត្តិធម៌ជាច្រើន ដែលប្រជាពលរដ្ឋមួយចំនួនបានជាប់ពន្ធនាគារ ដែលតាមពិតពួកគាត់ពុំគួរជាប់នោះទេ ប្រសិនបើលិទ្ធិប្រជាធិបតេយ្យដំណើរការបានត្រឹមត្រូវនោះ។ មានករណីមួយបានកើតមាននៅក្នុងខែធ្នូ ឆ្នាំ២០១០ ដែលបុគ្គលម្នាក់ត្រូវបានចាប់ខ្លួននៅថ្ងៃសុក្រ ពីបទការញុះញង់ ហើយត្រូវបានតុលាការជំនុំជម្រះ និងផ្តន្ទាទោសនៅក្នុងចុងសប្តាហ៍ដដែលនោះតែម្តង ដែលតាមធម្មតានៅចុងសប្តាហ៍ តុលាការមិនធ្វើការទេ។ ការដែលតុលាការនេះប្រើរយៈពេលតែពីរថ្ងៃ គិតពីថ្ងៃឃាត់ខ្លួនដល់ថ្ងៃជំនុំជម្រះ ហើយចំថ្ងៃចុងសប្តាហ៍ទៀតនោះ ការអនុត្តន៍បែបនេះនាំឲ្យគេមានការមន្ទិលជាខ្លាំងអំពីសមត្ថភាពរបស់តុលាការមួយនេះ ក្នុងការគោរពតាមបទដ្ឋានស្តីពីការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រឹមត្រូវនិងយុត្តិធម៌ ដែលត្រូវបានកំណត់ក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ចំណែកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលគេស្គាល់ថា តុលាការខ្មែរក្រហម) ៖ ខ្ញុំនៅតែរក្សាជំហររបស់ខ្ញុំ មិនផ្តល់សេចក្តីអធិប្បាយណាមួយលើបញ្ហាដែលតុលាការនេះ *កំពុងចាត់ការ* នាពេលបច្ចុប្បន្នទេ។ ទោះ

ជាដូច្នេះក្តី ខ្ញុំសូមស្នើយ៉ាងទទូចដល់មន្ត្រីទាំងអស់នៃតុលាការនេះ សូមធ្វើឲ្យប្រាកដថាការកាត់សេចក្តីនេះនឹងធ្វើជាគំរូមួយនៃដំណើរការយុត្តិធម៌ត្រឹមត្រូវ និងអាចជឿទុកចិត្តបាន សំរាប់ប្រជាពលរដ្ឋកម្ពុជា។

ទាំងអស់នេះគឺជាឧទាហរណ៍ខ្លះនៃបញ្ហាប្រឈមរបស់កម្ពុជា ហើយគោលដៅរបស់ខ្ញុំគឺធ្វើការជាមួយរាជរដ្ឋាភិបាលក្នុងន័យស្ថាបនា និងក្នុងស្មារតីនៃកិច្ចសហប្រតិបតិការ។ ដោយសារតែហេតុផលនេះហើយ ទើបបានជារបាយការណ៍ចុងក្រោយរបស់ខ្ញុំ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាតិ បានផ្តោតលើប្រព័ន្ធតុលាការ និងបានបញ្ចូលអនុសាសន៍មួយចំនួនដែលតាក់តែងឡើងដើម្បីពង្រឹងសមត្ថភាព និងឯករាជ្យភាពរបស់តុលាការ និងដើម្បីដកការបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតចេញពីបទល្មើសព្រហ្មទណ្ឌ លុះត្រាតែអំពើទាំងនេះ ដាក់ការគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ។ ដៃគូរសន្ទនានានារបស់រដ្ឋាភិបាលបានបញ្ជាក់ប្រាប់ខ្ញុំថាពួកគាត់នឹងពិនិត្យសិក្សាលើអនុសាសន៍របស់ខ្ញុំ និងពន្លឿនដល់កម្មវិធីខាងនីតិកម្ម ដើម្បីពង្រឹងប្រព័ន្ធតុលាការ។ ជាអាទិ៍ ខ្ញុំមានការពេញចិត្ត ដោយឃើញថា ច្បាប់រៀបចំអង្គការស្តីពីប្រព័ន្ធតុលាការដែលបានអូសបន្លាយពេល ដ៏យូរមកហើយនោះ នៅទីបំផុតបាននឹងកំពុងដំណើរការទៅមុខ។

ជាទីបំផុត ខ្ញុំទទួលបានកិច្ចសហប្រតិបត្តិការក្នុងកម្រិតដ៏ល្អមួយពីរាជរដ្ឋាភិបាល សភា និង អ្នកពាក់ព័ន្ធឯទៀតនៅក្នុងសង្គមកម្ពុជា ហើយខ្ញុំសង្ឃឹមរីករាយនឹងបន្តកិច្ចសហប្រតិបត្តិការរបស់ខ្ញុំជាមួយអ្នកទាំងនោះ។ ខ្ញុំនឹងដាក់របាយការណ៍បន្ទាប់របស់ខ្ញុំទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនាពេលដ៏ឆាប់ខាងមុខ ដែលក្នុងនោះ ខ្ញុំមានបំណងលើកឡើងអំពីអនុសាសន៍របស់ខ្ញុំក្នុងការពង្រឹងសមត្ថភាព និងឯករាជ្យភាពរបស់សភា។

ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ចំពោះការជួយឧបត្ថម្ភគាំទ្រផ្នែកភស្តុភារ និងបច្ចេកទេសដល់ការងាររបស់ខ្ញុំ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់អំពីសារៈសំខាន់នៃវត្តមានរបស់ការិយាល័យនេះនៅកម្ពុជា គឺដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្សបន្តទៀត។

ចប់

*Professor Surya P. Subedi was appointed by the UN Human Rights Council as the UN Special Rapporteur for Human Rights in Cambodia in March 2009. He is currently Professor of International Law at the University of Leeds in the United Kingdom.*

*All media requests related to the Special Rapporteur can be addressed to the Cambodian Office of the High Commissioner for Human Rights. Please contact Zoe Latumbo (Tel: +855 012790178 / email: zlatumbo@ohchr.org) or Huan Touch (Tel: +855 012 476 493 / email: htouch@ohchr.org).*